# វេទិកាកុមារអាស៊ានលើកទី ៦ (6th ACF)
# ស្តីពី
# ផលប៉ះពាល់នៃជំងឺកូវីដ -១៩ និងស្ថានភាពបច្ចុប្បន្នចំពោះកុមារ

ថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២០

## អនុសាសន៍

វេទិកាកុមារអាស៊ានលើកទី ៦ ត្រូវបានរៀបចំឡើងដោយមន្ត្រីជាន់ខ្ពស់សុខុមាលភាព និងការអភិវឌ្ឍន៍សង្គម (SOMSWD) ក្រោមការដឹកនាំរបស់ប្រទេសកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ។ ក្រោមមូលបទ "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងស្ថានភាពបច្ចុប្បន្នរបស់កុមារ" វេទិកាបានផ្តល់ឱកាសសម្រាប់តំណាងកុមារ មកពីបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ ដើម្បីពិភាក្សាបញ្ហាដែលប៉ះពាល់ ដល់វិស័យសុខាភិបាល ការអប់រំ ជីវភាពរស់នៅ និងបញ្ហាផ្សេងទៀតនៅចំពេលការរាតត្បាតជំងឺកូវីដ-១៩ កើតឡើង ។

ដើម្បីឆ្លើយតបទៅនឹងកង្វល់ទាំងនេះ កុមារអាស៊ានបានស្នើនូវអនុសាសន៍ទាក់ទងទៅកុមារខ្លួនឯង ឪពុកម្តាយ សហគមន៍ សាលារៀន និងអ្នកអប់រំ មន្ត្រីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ អនុសាសន៍នេះមានគោលបំណងដើម្បីដឹកនាំឆ្ពោះទៅរកសកម្មភាពក្នុងការផ្តល់សេវាកម្មនានា និងការគាំទ្រដល់កុមារ ជាពិសេសកុមារងាយរងគ្រោះបំផុត ដោយស្របតាមជំនាញនិងបទពិសោធន៍ក្នុងការឆ្លើយតបនឹងឧត្តមប្រយោជន៍ កុមារក្នុងកំឡុងពេលជំងឺរាតត្បាតកូវីដ -១៩ និងផ្សេងពីនេះទៀត។

ខាងក្រោមនេះ ជាអនុសាសន៍ដែលបានស្នើឡើង ដោយវេទិកាកុមារអាស៊ានលើកទី ៦ ៖

### ចំពោះកុមារ

១. អនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមការណែនាំរបស់រដ្ឋាភិបាល។

២. ចែករំលែកព័ត៌មាន ដើម្បីឲ្យមានការយល់ដឹងបានល្អ អំពីការរាតត្បាតនៃជំងឺកូវីដ-១៩ និងវិធានការណ៍បង្ការការឆ្លង។ លើកទឹក ចិត្តមិត្តភ័ក្តិ និងក្រុមគ្រួសារឱ្យពាក់មុខគ្រប់ពេល លាងដៃឲ្យបានញឹកញាប់ អនុវត្តតាមគម្លាតសង្គម និងកុំទៅកន្លែងដែលមានមនុស្សច្រើន។

៣. បរិភោគរបបអាហារដែលមានសុខភាពល្អ និងមានតុល្យភាពជាមួយនឹងការទទួលបានវីតាមីននិងសារជាតុរ៉ែបន្ថែម ដើម្បីធ្វើអោយប្រព័ន្ធភាពស៊ាំរបស់រាងកាយមានភាពប្រសើរឡើង។

៤. ថែរក្សាស្មារតីសុទិដ្ឋិនិយម មានភាពសប្បាយៗ និងបណ្តុះគំនិតច្នៃប្រឌិតក្នុងកំឡុងពេលគម្លាតសង្គម តាមរយៈសកម្មភាពលេងជាក្រុម និងសកម្មភាពផ្សេងៗទៀតដូចជាគំនូរ អាន និងលេងឧបករណ៍ភ្លេង។

៥. ចែករំលែកជាមួយក្រុមគ្រួសារនៅពេលមានការលំបាក ឬអារម្មណ៍មិនល្អ ដើម្បីជួយ និងគាំទ្រភ្លាមៗ។ គាំទ្រមិត្តភ័ក្តិដើម្បីស្វែងរកជំនួយនៅពេលមានអារម្មណ៍សោកសៅ ឬថប់អារម្មណ៍។

៦. មានភាពវិជ្ជមានចំពោះការរៀនសូត្រ និងលើកទឹកចិត្តឲ្យរៀន។ ដឹងនិងរៀបចំសម្រាប់វិធីសាស្ត្រសិក្សាពីចម្ងាយផ្សេងៗគ្នាដែលសាលារៀនកំពុងប្រើប្រាស់សម្រាប់មេរៀន។ រៀនតាមអនឡាញ ប្រសិនបើអាចចូលរួមរៀន និងធ្វើកិច្ចការសាលាឲ្យអស់។

៧. និយាយទៅកាន់គ្រូ ប្រសិនបើពួកគេព្រួយបារម្ភ ថាតើមានការប៉ះពាល់ដល់ការប្រលងរបស់ពួកគេ។ ដើម្បីចែករំលែកជាមួយគ្រួសារ សាលារៀន ដោយទទួលស្គាល់ថា ការរៀនតាមអនឡាញមានកម្រិត និងស្វែងរកដំណោះស្រាយ ដើម្បីជំនះឧបសគ្គទាំងនេះ។

៨. រៀនពីដំណោះស្រាយឌីជីថល ដើម្បីចូលរួមក្នុងកម្មវិធីសិក្សាតាមអនឡាញ។ ស្រូបយកស្មារតីសុទិដ្ឋិនិយម ដើម្បីទទួលយក និងត្រៀមខ្លួនសម្រាប់ជំនាញចាំបាច់ព្រោះវាត្រូវបានកំណត់ថាការរៀនសូត្រតាមអនឡាញគឺ ជានិន្នាការដែលមិនអាចជៀសរួចនៃយុគសម័យបដិវត្តឧស្សាហកម្ម ៤.០ បាន។

៩. មិនរើសអើងអ្នកណាម្នាក់ដែលខំតស៊ូ ដើម្បីចិញ្ចឹមជីវិត។
១០. និយាយចេញប្រសិនបើមានកុមារៗ ដែលអាចប្រឈមនឹងគ្រោះថ្នាក់ដោយសារស្ថានភាពគ្រួសារលំបាក។
១១. ប្រតិភូកុមារសមាជិកអាស៊ាននីមួយៗ បង្កើតវីដេអូអំពីគំនិត និងទស្សនៈរបស់ពួកគេ ហើយប្រមូលវីដេអូទាំងអស់នេះដាក់ចូលក្នុងវីដេអូតែមួយ។
១២. ស្វែងយល់ពីការរៀនសូត្រអន្តរវ័យ ជាមួយឪពុកម្តាយ និងរៀននូវអ្វីៗជាច្រើនតាមដែលអាចធ្វើទៅបាន ពីឪពុកម្តាយ ដូចជាការធ្វើម្ហូប ឬការអនុវត្តន៍វប្បធម៌ផ្សេងទៀត។
១៣. ធ្វើកិច្ចសាសនាជារៀងរាល់ថ្ងៃស្របទៅតាមសាសនារៀងៗខ្លួនដូចជាការបួងសួង ការរាប់អង្កាំ សមាធិ និងចែករំលែកសេចក្តីសន្តានចិត្ត ដោយសេចក្តីស្រឡាញ់ជាមួយនរណាម្នាក់នៅលើពិភពលោក ដើម្បីអាចទទួលបានសមានចិត្ត និងចិត្តស្ងប់។

**ចំពោះឪពុកម្តាយ និងគ្រួសារ**

១. លើកទឹកចិត្តកុមារឲ្យលាងដៃអោយបានត្រឹមត្រូវដោយប្រើសាប៊ូ ឧបករណ៍លាងសំអាតដៃ និងសម្ភារៈការពារផ្ទាល់ខ្លួននៅក្នុងផ្ទះ សាលារៀន កន្លែងសុខភាព និងកន្លែងសាធារណៈក្នុងពេលមានការរាតត្បាតជំងឺ ។ ត្រូវប្រាកដថាកូនៗ របស់ពួកគេមានសាប៊ូ ដែល ឬឱសថ អាល់កុល សម្រាប់លាងដៃឱ្យបានទៀងទាត់។

២. ដឹងនៅពេលណាដែលកុមារអាចត្រូវការការគាំទ្របន្ថែមទៀតសម្រាប់សុខភាពផ្លូវចិត្ត។ ស្វែងរកការគាំទ្រពីអ្នកជំនាញសម្រាប់ខ្លួនគេនិងកូនៗ ប្រសិនបើកម្មវិធីជំងឺកូវីដ -១៩ មានផលប៉ះពាល់អវិជ្ជមានដល់ពួកគេ ឬសុខភាពផ្លូវចិត្តរបស់កូនៗ។
៣. ចំណាយពេលវេលាមានតម្លៃជាមួយកូនៗ។
៤. ធ្វើបច្ចុប្បភាពស្តីពីស្ថានភាពជំងឺកូវីដ-១៩ពីប្រភពដែលគួរឲ្យទុកចិត្តបាន។
៥. ស្តាប់កុមារអំពីការលំបាកនៃការរៀនតាមអនឡាញ និងស្វែងរកដំណោះស្រាយដើម្បីជំនះឧបសគ្គទាំងនេះ។
៦. លើកទឹកចិត្តកុមារឲ្យបន្តការសិក្សាដោយឧស្សាហ៍ព្យាយាម សូម្បីតែមិនទៅសាលារៀនដោយផ្ទាល់ក៏ដោយ។ ផ្តល់ជូនកូនៗ នូវសំម្ភារៈ និងបរិស្ថានដែលចាំបាច់សំរាប់ធ្វើកិច្ចការផ្ទះ វគ្គសិក្សា និងសិក្សាអោយអស់ពីសមត្ថភាព។
៧. កុំដាក់សម្ពាធលើកុមារដែលមានការរំពឹងខ្ពស់នៃឧត្តមភាពការសិក្សានៅពេលការអប់រំ និងការប្រឡងមិនប្រាកដប្រជា។
៨. អោយប្រាកដថាកុមារទទួលបានអាហារមានជីវជាតិទាំងនៅក្នុងក្រុងនិងនៅជនបទ។
៩. គាំទ្រអ្នកជិតខាងដែលកំពុងតស៊ូដោយគាំទ្រអាជីវកម្មរបស់ពួកគេ។
១០. ស្វែងយល់ពីការរៀនសូត្រអន្តរវ័យ ជាមួយកូនៗ និងរៀននូវអ្វីៗជាច្រើនតាមដែលអាចធ្វើទៅបានពីកូនៗ របស់ពួកគេដូចជាបច្ចេកវិទ្យាជាដើម។

១១. អនុញ្ញាតឲ្យកុមារធ្វើកិច្ចសាសនាជារៀងរាល់ថ្ងៃស្របតាមសាសនារៀងៗខ្លួនដូចជាការបួងសួង ការរាប់អង្កាំ សមាធិ ស្តាប់ការប្រដៅសាសនា ការចែករំលែកសន្តានចិត្ត និងអាកប្បកិរិយាប្រកបដោយសេចក្តីស្រឡាញ់ជាមួយនរណាម្នាក់នៅលើពិភពលោកឲ្យមានស្មារតី និងមានសន្តិភាពផ្លូវចិត្ត។

**ចំពោះសាលារៀន និងគ្រូបង្រៀន**

១. លើកទឹកចិត្តកុមារឲ្យលាងដៃអោយបានត្រឹមត្រូវដោយប្រើសាប៊ូអនាម័យដៃ និងឧបករណ៍ការពារផ្ទាល់ខ្លួននៅក្នុងផ្ទះសាលារៀនកន្លែងសុខភាព និងកន្លែងសាធារណៈ ក្នុងពេលមានការរាតត្បាតជំងឺ ។

២. ផ្តល់ព័ត៌មានថ្មីៗដល់កុមារអំពីស្ថានភាពបច្ចុប្បន្ននៃការរាតត្បាតជំងឺ ។
៣. ផ្តល់ម៉ាសពាក់មុខដល់កុមារម្នាក់ៗ ជារៀងរាល់ថ្ងៃដើម្បីឲ្យកុមារទាំងអស់មានសុវត្ថិភាពទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ វាស់កំដៅកុមារ មុនពេលកុមារចូលសាលារៀនហើយមិនអនុញ្ញាតឲ្យសិស្សណាម្នាក់ចូលរៀនឡើយប្រសិនបើពួកគេក្តៅខ្លួន។

៤. ត្រូវប្រាកដថាកុមារមានលទ្ធភាពចូលរួមក្នុងសកម្មភាពដែលទាក់ទងនឹងសង្គម។ លើកទឹកចិត្តគ្រូបង្រៀនឲ្យដឹងពីសញ្ញានៃបញ្ហាសុខភាពផ្លូវចិត្ត និងដឹងថាត្រូវធ្វើអ្វីខ្លះប្រសិនបើពួកគេឃើញសញ្ញាបែបនេះចំពោះសិស្សរបស់ពួកគេ។ ត្រូវមានអ្នកប្រឹក្សាយោបល់នៅសាលា ដែលកុមារអាចទៅជួបបាន ប្រសិនបើនៅពេលដែលពួកគេមានអារម្មណ៍ថាពួកគេត្រូវការ។
៥. វិនិយោគលើបច្ចេកវិទ្យាឌីជីថល អភិវឌ្ឍកម្មវិធីអក្ខរកម្មឌីជីថល ពង្រីកលទ្ធភាពទទួលបានសេវាអ៊ិនធឺណិត។ បណ្តុះបណ្តាលគ្រូបង្រៀនឲ្យប្រើវិធីសាស្ត្របង្រៀនតាមអនឡាញ និងពីចម្ងាយ។
៦. ស្តាប់កុមារអំពីការលំបាកនៃការរៀនតាមអនឡាញ និងស្វែងរកដំណោះស្រាយដើម្បីជំនះឧបសគ្គទាំងនេះ។
៧. ផ្តល់មេរៀនជម្រើសដល់កុមារដែលមិនមានឧបករណ៍ប្រើប្រាស់។
៨. អោយប្រាកដថាកុមារគ្រប់រូបគួរទទួលបានការប្រលងឲ្យបានពេញលេញចំពោះការសិក្សា។
៩. លើកទឹកចិត្តគ្រូបង្រៀនទាំងអស់ឲ្យមានទឹកចិត្តនិងបន្តផ្តល់ការបង្រៀនប្រកបដោយគុណភាពទោះបីកុមារមិនបានរៀនគ្រប់គ្រាន់នៅក្នុងថ្នាក់ក៏ដោយ។
១០. ដឹងឥរិយាបថ អាកប្បកិរិយា សុខភាព ឬការចូលរៀនរបស់កុមារមានការផ្លាស់ប្តូរភ្លាមៗហើយកាន់តែអាក្រក់ទៅ បន្ទាប់មករាយការណ៍ទៅមនុស្សដែលត្រឹមត្រូវ និងទុកចិត្តបាន។
១១. បន្ថយ ឬកាត់បន្ថយថ្លៃឈ្នួល និងថ្លៃផ្សេងៗទៀតសម្រាប់គ្រួសារដែលកំពុងតស៊ូផ្គត់ផ្គង់ដោយខ្លួនឯង។
១២. ត្រួតពិនិត្យស្ថានភាពសិស្ស ជាប្រចាំ ជាពិសេសអ្នកដែលមានហានិភ័យ ឬផលប៉ះពាល់ដោយរោគរាតត្បាត។

**ចំពោះអ្នកដឹកនាំសហគមន៍**

១. ផ្តល់ព័ត៌មានដល់កុមារឲ្យបានទៀងទាត់អំពីស្ថានភាពបច្ចុប្បន្ន។ បង្ហាញផ្ទាំងរូបភាពដែលមានរូបភាពនិងងាយយល់ភាសាដើម្បីឲ្យកុមារយល់ដឹងពីរបៀបដែលពួកគេអាចការពារខ្លួនឯងបាន។
២. ប្រាកដថាមានតំបន់និងការសម្របសម្រួលដែលកុមារអាចចូលរួមបាន ក្នុងសកម្មភាពដែលទាក់ទងនឹងគម្លាតសង្គម។ ធ្វើឲ្យវាមានសុវត្ថិភាពសម្រាប់មនុស្សដែលត្រូវការការគាំទ្រជាមួយនឹងសុខភាពផ្លូវចិត្ត ដើម្បីសុំជំនួយ ដោយកាត់បន្ថយការរើសអើងនិងការមាក់ងាយ។
៣. តាមដានសាលាក្នុងមូលដ្ឋានប្រសិនបើមេរៀនមិនត្រូវបានផ្តល់អោយ។ លើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមគាំទ្រកូនធ្វើកិច្ចការសាលា។
៤. ប្រាកដថាសាលាក្នុងមូលដ្ឋានផ្តល់ឲ្យកុមារនូវគុណភាពនៃការបង្រៀន និងមេរៀនឲ្យបានច្រើនសម្រាប់ការប្រឡង។
៥. ទទួលស្គាល់ថាគុណវុឌ្ឍិដែលទទួលបាននៅឆ្នាំនេះ មានតម្លៃដូចគ្នាជារៀងរាល់ឆ្នាំហើយប្រាកដថាអ្នករាល់គ្នាដឹងច្បាស់។
៦. អ្នកដឹកនាំសហគមន៍គួរធានាថាកុមារអាចទទួលបានអាហារមានជីវជាតិល្អទាំងនៅទីក្រុងនិងនៅជនបទ។
៧. គាំទ្រអាជីវកម្មក្នុងស្រុក។ ចែករំលែកធនធានជាមួយអ្នកដែលកំពុងតស៊ូ ដើម្បីផ្គត់ផ្គង់ពួកគេនិងគ្រួសារ។

**ចំពោះរដ្ឋាភិបាល**

១. ធានាឲ្យមានការបន្តនិងពេញលេញនៃសេវាថែទាំសុខភាព ដូចជាការសំរាលកូនមុននិងក្រោយពេល ការចាក់វ៉ាក់សាំងជាប្រចាំជាពិសេសការដាក់ពង្រាយក្រុមថែទាំសុខភាពចល័ត / ការចុះតាមផ្ទះ ដើម្បីផ្តល់ការថែទាំសុខភាពចាំបាច់ភ្លាមៗ។ ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ។
២. ផ្តល់កញ្ចប់អនាម័យដល់អ្នកដែលប្រឈមនឹងការឆ្លងវីរុស និងអ្នកងាយរងគ្រោះបំផុតនៅក្នុងសង្គម។
៣. ប្រាកដថាព័ត៌មានអំពីការការពារជំងឺកូវីដ-១៩ កុមារអាចទទួលបាន។ ផ្តល់ព័ត៌មានដល់កុមារឲ្យបានទៀងទាត់អំពីស្ថានភាពបច្ចុប្បន្ន។
៤. ទទួលស្គាល់ថាស្ថានភាពជំងឺកូវីដ-១៩ អាចជះឥទ្ធិពលអវិជ្ជមានដល់សុខភាពផ្លូវចិត្តទាំងកុមារ និងមនុស្សពេញវ័យ។ ផ្តល់នូវគោលការណ៍ណែនាំសម្រាប់វិធីដែលកុមារអាចត្រូវបានគាំទ្រ ដើម្បីរួចផុតពីការប្រឈមសុខភាពផ្លូវចិត្ត ដែលបណ្តាលមកពីស្ថានភាពជំងឺកូវីដ-១៩។ ផ្តល់សេវាឥតគិតថ្លៃតាមអនឡាញ និងនៅក្រៅប្រព័ន្ធអនឡាញ ការប្រឹក្សាផ្នែកចិត្តសាស្ត្រចំពោះ

កុមារ និងយុវជន ផ្តល់សិទ្ធិអំណាចដល់កុមារ និងយុវជនដើម្បីបង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសុខភាពផ្លូវចិត្ត និងតាមផ្ទះនៅក្នុងសង្គម និងការអប់រំសម្រាប់ក្រុមគ្រួសារដែលយើងទៅមិនដល់ តាមតំបន់ជនបទ។

៥. បង្កើតយុទ្ធនាការជាវីដេអូអំពី" តើសុខភាពផ្លូវចិត្តរបស់កុមារមានសារៈសំខាន់ប៉ុណ្ណាពេលការរាតត្បាតជំងឺកូវីដ-១៩" ។

៦. វិនិយោគលើបច្ចេកវិទ្យាឌីជីថល អភិវឌ្ឍកម្មវិធីអក្ខរកម្មឌីជីថល ពង្រីកលទ្ធភាពទទួលបានសេវាអ៊ីនធើណេត។

៧. ផ្តល់ជម្រើសឲ្យបានច្រើន សម្រាប់ទទួលបានការអប់រំនៅខាងក្រៅថ្នាក់រៀន ដើម្បីឲ្យកុមារដែលមិនមានឧបករណ៍ និងអ៊ិនធើណេត អាចចូលរួមមេរៀនបាន។ ផ្តល់សាលារៀននូវគោលការណ៍ណែនាំល្អៗសម្រាប់គ្រូបង្រៀន ដូច្នេះពួកគេដឹងនូវអ្វីដែលគេបានរំពឹងទុករបស់ពួកគេ។ ធ្វើសេចក្តីប្រកាសឱ្យបានច្បាស់លាស់លើការសម្រេចចិត្តដែលប៉ះពាល់ដល់ការប្រឡង។ ធានាថាប្រព័ន្ធដែលធ្លាប់ប្រើសម្រាប់ដាក់ពិន្ទុសិស្សគឺដូចគ្នានៅទូទាំងប្រទេស។

៨. ធ្វើគោលនយោបាយដើម្បីគាំទ្រឪពុកម្តាយទាំងឡាយណាដែលកំពុងធ្វើការ និងអ្នកទាំងឡាយណាដែលមានសមត្ថភាពមានកម្រិត ក្នុងការរស់នៅពីព្រោះពួកគេរងផលប៉ះពាល់ដោយជំងឺរាតត្បាតកូជំងឺ។

៩. ធានាថាកុមារមានលទ្ធភាពទទួលបានអាហារបំប៉នទាំងនៅទីក្រុងនិងជនបទ។

១០. ធានាថាអាជ្ញាធរមូលដ្ឋានកំណត់ថាតើមានកុមារប៉ុន្មាននាក់ ដែលជាជនងាយរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ លើជីវភាពគ្រួសារ។

១១. ផ្តល់ជំនួយជាបន្ទាន់ដល់គ្រួសារដែលត្រូវបានកំណត់ថាមានតម្រូវការ។

១២. បង្កើត និងចែកចាយសៀវភៅជាអេឡិចត្រូនិក នៃគោលការណ៍ណែនាំ ភាពរឹងមាំ គ្រួសារ ប្រកបដោយភាពច្នៃប្រឌិតប្រឆាំងនឹង Covid-19 និងផ្តល់ព័ត៌មានអំពីបញ្ហានេះ (ជាភាសាប្រទេសសមាជិកអាស៊ាន ទាំងអស់)។

១៣. អនុវត្តការស្ទង់មតិជាប្រព័ន្ធ ដើម្បីដឹងពីចំនួនកុមារពិតប្រាកដដែលត្រូវការជំនួយ ផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀត ជួយពួកគេ និងលើកទឹកចិត្តដល់អ្នកដែលមានជីវភាពធូរធារឱ្យចូលរួមនៅក្នុងដំណើរការសប្បុរសធម៌។

១៤. អោយសាធារណជនដឹងពីការលំបាក ដើម្បីឲ្យអ្នកស្ម័គ្រចិត្តអាចចូលរួមវិភាគទានបាន។

## ចំពោះអង្គការមិនមែនរដ្ឋាភិបាល

១. គាំទ្រកុមារងាយរងគ្រោះ (រាប់បញ្ចូលទាំងអ្នកមើលថែទាំជំនួស ការរស់នៅតាមផ្លូវ កុមារពិការ) ត្រូវតែមានសិទ្ធិទទួលបានព័ត៌មានដូចគ្នាអំពីវិធីការពារជំងឺកូវីដ-១៩ ដូចកុមារដែលរស់នៅជាមួយគ្រួសារដែរ។

២. ប្រាកដថាកុមារងាយរងគ្រោះទទួលបានសាប៊ូ ដែល ឬអាល់កុលមានជាតិឱសថសម្រាប់លាងដៃឲ្យបានទៀងទាត់។ ផ្តល់កញ្ចប់អនាម័យដល់អ្នកដែលងាយប្រឈមនឹងការឆ្លងវីរុស និងជនងាយរងគ្រោះបំផុតនៅក្នុងសង្គម។

៣. ផ្តល់សេវាកម្មសុខភាពផ្លូវចិត្តដល់កុមារងាយរងគ្រោះ (រួមទាំងអ្នកថែទាំជំនួស ការរស់នៅតាមដងផ្លូវ កុមារពិការ) ។

៤. គាំទ្រកុមារងាយរងគ្រោះក្នុងការប្រើប្រាស់អ៊ិនធើណេត និងវិធីសាស្ត្រពីចំងាយ ដទៃទៀតក្នុងការអប់រំ។ ណែនាំកុមារងាយរងគ្រោះជាមួយនឹងឧបករណ៍ និងកម្មវិធីរៀនតាមអនឡាញដែលមានសុវត្ថិភាព ជាពិសេសសម្រាប់កុមារនៅតំបន់ដាច់ស្រយាល។

៥. ផ្តល់ការគាំទ្រដល់កុមារដែលមានប្រព័ន្ធភាពស៊ាំមិនដំណើរការ ឬជាជនពិការ និងគ្រួសាររបស់ពួកគេ។

៦. ផ្តល់កញ្ចប់ស្បៀងជាបន្ទាន់ដល់គ្រួសារដែលកំពុងជួបការលំបាកដោយសារជំងឺរាតត្បាតកូវីដ-១៩ ។

៧. គាំទ្រដល់គ្រួសារដែលជីវភាពរបស់ពួកគេរងផលប៉ះពាល់អវិជ្ជមានដោយជំងឺកូវីដ-១៩ ជាមួយសេវាកម្មបង្កើនប្រាក់ចំណូល។

---------